**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់ហេតុប្រជុំ

## ស្ដីពីករណីព្យួរកិច្ចសន្យាការងារ

ឆ្នាំពីរពាន់ម្ភៃបី ខែ កុម្ភៈ ថ្ងៃទី ម្ភៃប្រាំពីរ វេលាម៉ោងប្រាំបួន និងសាមសិប នាទីព្រឹក មានកិច្ចប្រជុំមួយនៅសាលប្រជុំក្រុមហ៊ុន យីង ស៊ាង សេង ហ្គាម៉ិន ឯ.ក ដែលមានទីតាំងស្ថិតនៅភូមិ ព្រែកសំរោង ក្រុងតាខ្មៅ ខេត្តកណ្ដាល ស្ដីពីករណីព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ក្រោមអធិបតីភាពលោក QUE WENLOU ជានាយកក្រុមហ៊ុនដោយមានការចូលរួមពីលោក-លោកស្រីសហជីព៣ និង ប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ។

ជាកិច្ចចាប់ផ្ដើម លោកនាយក QUE WENLOU បានបើកកិច្ចប្រជុំ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ លោក-លោកស្រី ជាភាគីតំណាង កម្មករនិយោជិត (ប្រតិភូបុគ្គលិក) ដែលបានចំណាយពេលអញ្ជើញចូលរួមប្រជុំនៅថ្ងៃនេះ ។ បន្ទាប់មក លោកនាយកក្រុមហ៊ុន បានជម្រាបជូនលោក-លោកស្រីជាសមាជិកអង្គប្រជុំអំពីមូលហេតុដែលក្រុមហ៊ុនសម្រេចស្នើរសុំព្យួរកិច្ចសន្យាការងារបងប្អូន កម្មករនិយោជិត យ៉ាងដូច្នេះថា៖ មួយរយៈចុងក្រោយនេះក្រុមហ៊ុនបានជួបប្រទះនូវការធ្លាក់ចុះការបញ្ជាទិញពីភ្ញៀវ ទើបក្រុមហ៊ុនសម្រេចស្នើរសុំព្យួរកិច្ចសន្យាការងារបងប្អូន កម្មករនិយោជិត មួយរយៈពេល ។

ភាគីតំណាង កម្មករនិយោជិត (ប្រតិភូបុគ្គលិក) ឯកភាពទាំងស្រុងចំពោះការលើកឡើងរបស់លោកនាយកក្រុមហ៊ុន ក្នុងនោះតាមការសង្កេតជាក់ស្ដែង គឺក្រុមហ៊ុនពិតជាមិនមានការងារគ្រប់គ្រាន់ជូនបងប្អូន កម្មករនិយោជិតពិតប្រាកដមែន ។ ក្រោយពីបានពិភាក្សា និង សហការណ៍គ្នាយ៉ាងមុតមាំរួចមក អង្គប្រជុំសម្រេចបានលទ្ធផលដូចខាងក្រោម ៖

១-ក្រុមហ៊ុនសម្រេចព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត សរុបទាំងអស់ចំនួន ៥៨១ នាក់ រយៈពេល ០២ខែ ដោយចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ ២០២៣ រហូតដល់ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២៣ ។

២-ភាគីក្រុមហ៊ុនឯកភាពផ្ដល់ប្រាក់ឧបត្ថម្ភចំនួន ៣០ ដុល្លាអាមេរិក (សាមសិបដុល្លាអាមេរិក) ក្នុងរយៈពេល០១ខែ ហើយក្រុមហ៊ុននឹងបើកប្រាក់ឧបត្ថម្ភជូនបងប្អូន កម្មករនិយោជិត មុនពេលព្យួរកិច្ចសន្យាការងារ ។

៣-ប្រសិនបើក្រុមហ៊ុនទទួលបានការបញ្ជាទិញពីម្ចាស់ទំនិញឡើងវិញ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងជូនដំណឹងឱ្យបងប្អូន កម្មករនិយោជិតត្រលប់ចូលធ្វើការវិញតាមក្រុមរៀងៗខ្លួន ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១១:០០ នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសយោគយល់អធ្យាស្រ័យ និងស្និទ្ធស្នាលគ្នា ។

| **នាយកក្រុមហ៊ុន** | **តំណាងកម្មករនិយោជិត** | | **លេខាកត់ត្រា** |
|---|---|---|---|
| ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យីង ស៊ាង សេង ហ្គាមិន ឯ.ក YING XIANG SHENG GARMENT CO.,LTD. KINGDOM OF CAMBODIA | ពុត សាមឿន | ហេង សុខឃីម | |
| QUE WENLOU | កែវ ច័ន្ទថុល | អឿន ផល្លី | សម ចរិយា |
| | ហេង សុភាព | ចក់ ថារិទ្ធ | |